**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ......០៨......សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មការអន្តរក្រសួង**
**រៀបចំកិច្ចប្រជុំគុម្ពលចិនលើកទី៥**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

**សម្រេច**

**ប្រការ១.**

ត្រូវបានបង្កើត "គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំគុម្ពលចិនលើកទី៥" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ដូចមានសមាសភាពខាងក្រោមៈ



www.pheakdeylaw.com

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥. រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៦. រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩. រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០. រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១. រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៣. រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៤. រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៥. រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៦. រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៧. រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១៩. អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២០. មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២១. អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២២. អគ្គលេខាធិការរងគណៈកម្មការវិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៣. អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៤. អគ្គនាយក នៃអគ្គនាយដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២៥. អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| ២៦. អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ២៧. អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ២៨. ប្រធានមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប | សមាជិក |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំគុមូលចិនលើកទី៥ មានភារកិច្ចដឹកនាំ ចាត់ចែង និងរៀបចំកិច្ចប្រជុំគុមូលចិនលើកទី៥ ឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ គណៈកម្មការអន្តរក្រសួងនេះ អាចបង្កើតលេខាធិការដ្ឋាន អនុគណៈកម្មការ និងក្រុមការងារជំនាញដែលមានការចូលរួមដោយមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់។ លេខាធិការដ្ឋាន អនុគណៈកម្មការ និងក្រុមការងារជំនាញ ត្រូវបានបង្កើតឡើងដោយប្រកាសក្រសួងពាណិជ្ជកម្ម។



www.pheakdeylaw.com

**ប្រការ ៣.-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំគុម្ពលចិនលើកទី៥ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់ភារកិច្ចពីប្រធាន។ គណៈកម្មការអន្តរក្រសួងនេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់។

**ប្រការ ៤.-**

ការចំណាយសម្រាប់ដំណើរការរៀបចំកិច្ចប្រជុំគុម្ពលចិនលើកទី៥ ត្រូវយកពីថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងពាណិជ្ជកម្ម ឬថវិកាទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

**ប្រការ ៥.-**

គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដំណើរការការងារ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com